# សារៈសំខាន់នៃការតាមដានត្រួតពិនិត្យ និងវាយតម្លៃការគ្រប់គ្រងប្រតិបត្តិការ

គ្រប់ស្ថាប័នទាំងអស់ តែងចង់សម្រេចឱ្យបាននូវលទ្ធផលតាមផែនការសកម្មភាពដែលបានដាក់ចេញស្របទៅតាមចក្ខុវិស័យ គោលដៅ គោលបំណង និងបេសកកម្មរបស់ខ្លួន។ ដូច្នេះដើម្បីធានាបានថា ការអនុវត្តការងារប្រចាំថ្ងៃរបស់ស្ថាប័នស្របទៅតាមផែនការសកម្មភាព លុះត្រាតែស្ថាប័ននោះរៀបចំនូវយន្តការនីតិវិធីតាមដានត្រួតពិនិត្យ និងវាយតម្លៃសម្រាប់ការគ្រប់គ្រងប្រតិបត្តិការ។

**តើការតាមដានត្រួតពិនិត្យ និងវាយតម្លៃការគ្រប់គ្រងប្រតិបត្តិការផ្តល់សារៈសំខាន់អ្វីខ្លះដល់ស្ថាប័ន?**






ការតាមដានត្រួតពិនិត្យ និងវាយតម្លៃ ដើរតួនាទីយ៉ាងសំខាន់នៅក្នុងកិច្ចប្រតិបត្តិការនានារបស់ស្ថាប័ន និងដើម្បីធានាថាស្ថាប័ននោះ បានអនុវត្តការងារស្របទៅតាមផែនការដែលបានកំណត់។ បន្ថែមពីនេះ ការតាមដានត្រួតពិនិត្យ និងវាយតម្លៃក៏ជួយឱ្យស្ថាប័នអនុវត្តកិច្ចការនានាប្រកបទៅដោយប្រសិទ្ធភាព ស័ក្តិសិទ្ធិភាព និងភាពសន្សំសំចៃ។

ការតាមដានត្រួតពិនិត្យ និងការវាយតម្លៃ គឺជាដំណើរការនៃការប្រមូលព័ត៌មានជាបន្តបន្ទាប់ និងដើម្បីធ្វើការវាយតម្លៃក្នុងគោលបំណងកំណត់ថាតើវឌ្ឍនភាពរបស់កិច្ចការងារនោះបាននឹងកំពុងឆ្ពោះទៅរកគោលដៅ និងគោលបំណងដែលបានកំណត់ទុកជាមុន ព្រមទាំងបញ្ជាក់អំពីផលប៉ះពាល់នានាដែលបង្កឡើងដោយការអនុវត្តសកម្មភាពការងារ។

ការតាមដានត្រួតពិនិត្យ និងការវាយតម្លៃ នឹងជួយដល់ស្ថាប័នក្នុងការទាញយកពីសកម្មភាពដែលបានអនុវត្ត ព័ត៌មាននានាដែលពាក់ព័ន្ធ និងលទ្ធផលដែលទទួលបាន ដើម្បីប្រើប្រាស់ជាមូលដ្ឋានសម្រាប់ការកែតម្រូវ ការតម្រង់ទិសឡើងវិញ និងការធ្វើផែនការនៅពេលអនាគត។ ប្រសិនបើស្ថាប័នមួយមិនមានការតាមដានត្រួតពិនិត្យ និងការវាយតម្លៃទេនោះ ស្ថាប័ននឹងមិនអាចវិនិច្ឆ័យបានទេ ថាការងារដែលកំពុងអនុវត្តនោះមានដំណើរការត្រឹមត្រូវស្របតាមទិសដៅដែលស្ថាប័នបានកំណត់ដែរ ឬទេ និងមិនអាចកំណត់បានថាស្ថាប័ននោះ មានភាពរីកចម្រើន ឬអត់ ជាពិសេសមិនអាចកំណត់បានថាសកម្មភាពការងារណាដែលត្រូវកែលម្អនាពេលអនាគត។

## ១. ការតាមដានត្រួតពិនិត្យ



ការតាមដានត្រួតពិនិត្យរៀបចំឡើងក្នុងគោលបំណងដើម្បីធ្វើការវាស់វែងពីការរីកចម្រើន និងការផ្លាស់ប្តូរនៅក្នុងស្ថានការណ៍ ឬសកម្មភាពដើម្បីពិនិត្យមើល ថាតើការអនុវត្តការងារកំពុងអនុវត្តទៅតាមផែនការដែលបានកំណត់ដែរឬទេ ព្រមទាំងពិនិត្យលើទិសដៅ និងធ្វើការសម្រេចចិត្តឱ្យបានត្រឹមត្រូវដើម្បីធ្វើឱ្យស្ថាប័នកាន់តែល្អប្រសើរឡើង។

ការតាមដានត្រួតពិនិត្យត្រូវធ្វើឡើងជាបន្តបន្ទាប់ គ្រប់ជំហានទាំងអស់នៃដំណើរការអនុវត្តសកម្មភាពប្រតិបត្តិការ។ ភាពញឹកញាប់នៃការតាមដានត្រួតពិនិត្យ គឺអាស្រ័យទៅលើកត្តា ៣ រួមមាន÷

- ទំហំនៃសកម្មភាព
- ស្ថានភាពនៃសកម្មភាព និង
- សមត្ថភាពមន្ត្រីទទួលបន្ទុកសកម្មភាពនោះ។

## ២. ការវាយតម្លៃ




ការវាយតម្លៃរៀបចំឡើងក្នុងគោលបំណងដើម្បីវាយតម្លៃពីភាពខ្លាំង និងភាពខ្សោយនៃការអនុវត្តផែនការរបស់ស្ថាប័ន រួចធ្វើការកែលម្អឱ្យមានប្រសិទ្ធភាព។ ការវាយតម្លៃត្រូវបានធ្វើឡើងពេលបញ្ចប់ការអនុវត្តសកម្មភាព នៅពាក់កណ្តាលការអនុវត្តសកម្មភាពដោយថ្នាក់ដឹកនាំ ។

## ៣. សារៈសំខាន់នៃការតាមដានត្រួតពិនិត្យ និងការវាយតម្លៃ

ការតាមដានត្រួតពិនិត្យ និងការវាយតម្លៃ នឹងជួយឱ្យស្ថាប័ន÷

- ស្វែងយល់ពីការរីកចម្រើននានា ដែលឆ្ពោះទៅសម្រេចបានគោលបំណង
- តាមដានពីប្រតិបត្តិការជាក់ស្តែង ដោយប្រៀបធៀបនឹងផែនការដែលបានដាក់ចេញ
- ធានាបាននូវការប្រើប្រាស់ធនធានប្រកបដោយប្រសិទ្ធភាព និងប្រសិទ្ធផលខ្ពស់
- បម្រើសេវាកម្មដល់សាធារណជនប្រកបដោយគុណភាព
- កំណត់បញ្ហាដែលអាច ឬកំពុងរាំងស្ទះប្រតិបត្តិការ និងឧបសគ្គនានាដែលពាក់ព័ន្ធដំណើរការការងារ
- ដោះស្រាយបញ្ហាប្រឈមក្នុងដំណើរការអនុវត្តផែនការសកម្មភាពបានទាន់ពេលវេលាក្នុងករណីចាំបាច់អាចកែលម្អផែនការឬដំណើរការប្រតិបត្តិការនានាដើម្បីទទួលបានសមិទ្ធផលសមស្របនាពេលអនាគត
- ធ្វើជាជំនួយស្មារតីដល់ថ្នាក់ដឹកនាំស្ថាប័នក្នុងការសម្រេចចិត្តសម្រាប់រៀបចំផែនការបន្ទាប់ប្រកបដោយប្រសិទ្ធភាព
- តម្រង់ទិសដៅការងារ។

**អត្ថបទ÷** កញ្ញា **សុធី មេត្តា**

**ឯកសារយោង÷**

១- ឧត្តមានុវត្តន៍នៃការគ្រប់គ្រងប្រតិបត្តិការរបស់អង្គភាពសវនកម្មផ្ទៃក្នុងនៃ **អ.ស.ហ.**

២- គោលការណ៍ណែនាំស្តីពីសវនកម្មសមិទ្ធកម្មរបស់អង្គភាពសវនកម្មផ្ទៃក្នុងនៃ **អ.ស.ហ.**